# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ០៤ សរណន

## សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងការគ្រប់គ្រង បញ្ជូន ឬចែករំលែកឯកសារផ្ទៃក្នុង មានវេទយិតភាពខ្ពស់ និងសម្ងាត់ ពាក់ព័ន្ធសមត្ថកិច្ចទីស្តីការគណៈរដ្ឋមន្ត្រី

ក្នុងគោលបំណងធានាសណ្តាប់ធ្នាប់ និងរបៀបរៀបរយ នៃការគ្រប់គ្រង បញ្ជូន ឬចែករំលែកឯកសារទាំងឡាយណាដែលមានវេទយិតភាពខ្ពស់ និងសម្ងាត់ ផ្ទៃក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រីសូមធ្វើការណែនាំដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកទាំងអស់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មេត្តាអនុវត្តឱ្យបានខ្ជាប់ខ្ជួនទៅតាមគោលការណ៍សំខាន់ៗចំនួន ៣(បី) ដូចខាងក្រោម៖

១- មិនអនុញ្ញាតឱ្យបញ្ជូន ឬចែករំលែកឯកសារ ដែលជាកិច្ចការផ្ទៃក្នុង ឬមានលក្ខណៈរសើប និងសម្ងាត់តាមគ្រប់រូបភាព ជាពិសេស តាមមធ្យោបាយប្រព័ន្ធអេឡិចត្រូនិក ឬតាមកម្មវិធីបណ្តាញទំនាក់ទំនងសង្គមនានា។

២- ត្រូវបង្កើនការប្រុងប្រយ័ត្ន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការគ្រប់គ្រង បញ្ជូន ឬ ចែករំលែកឯកសារសំខាន់ៗគ្រប់ប្រភេទ ជាពិសេស លិខិតបទដ្ឋានស្តីពីការតែងតាំង ឬលិខិតបទដ្ឋានឯកត្តបុគ្គលនានា ដែលមិនមានលក្ខណៈបម្រើប្រយោជន៍រួម ទៅកាន់បុគ្គល ឬសាធារណជនដែលគ្មានការពាក់ព័ន្ធ ព្រមទាំងចៀសវាងការចែកចាយឯកសារដោយអាណាធិបតេយ្យ ដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬជះឥទ្ធិពលអវិជ្ជមានមកលើទីស្តីការគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល។

៣- ត្រូវពង្រឹងការអនុវត្តក្រមសីលធម៌មន្ត្រីរាជការ តាមរយៈការប្រតិបត្តិឱ្យកាន់តែសកម្ម ចំពោះកាតព្វកិច្ចមន្ត្រីរាជការ ជាពិសេស ការរក្សាការសម្ងាត់វិជ្ជាជីវៈ ដោយមិនត្រូវផ្តល់ព័ត៌មានអំពីកិច្ចការក្នុងមុខងារផ្លូវការរបស់ខ្លួន ដល់បុគ្គលខាងក្រៅ ឬសាធារណជន ដោយពុំមានការអនុញ្ញាតពីប្រធានស្ថាប័ន។

ក្នុងករណីមន្ត្រីរូបណាអនុវត្តផ្ទុយពីគោលការណ៍ខាងលើ នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ដោយអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តតាមសេចក្តីណែនាំឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**ចម្លងជូន** :

- គ្រប់ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់អង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ